# សហភាពផ្ទះសាមគ្គខកចិត្តចំពោះអាជ្ញាធរជុំវិញការឃាត់ខ្លួនលោកថេង សាវឿននិងសហការី



*លោកថេង សាវឿន ប្រធានសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា*

សហភាពផ្ទះសាមគ្គី បានបង្ហាញការខកចិត្តយ៉ាងខ្លាំងចំពោះសកម្មភាពរបស់ស្នងការដ្ឋាននគរបាលខេត្តក្រចេះ និងអាជ្ញាធរខេត្តរតនគិរី ដែលបានប្រើប្រាស់អំណាចក្នុងការឃាត់ឡានក្រុងរបស់ក្រុមការងារសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា។ ការឃាត់ខ្លួននេះធ្វើឡើងនៅខេត្តក្រចេះវេលាម៉ោង១២:២០នាទីរសៀល នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ អំឡុងពេលរថយន្តក្រុងដឹកក្រុមការងារសមាគម

ធ្វើដំណើរចាកចេញពីខេត្តរតនគិរីឆ្លងកាត់ខេត្តក្រចេះ ដើម្បីត្រឡប់មកភ្នំពេញវិញក្រោយពេលដែលសមាគមបញ្ចប់វគ្គសិក្ខាសាលាពង្រឹងសមត្ថភាព និងកិច្ចប្រជុំឆ្លុះបញ្ចាំងការងារដល់បុគ្គលិករបស់ខ្លួន។ នេះបើយោងតាមសេចក្ដីថ្លែងការណ៍សហភាពផ្ទះសាមគ្គី។

សេចក្ដីថ្លែងការណ៍បានបញ្ជាក់បន្ថែមថា នៅលើឡានក្រុងនោះមានបុគ្គលិក និងក្រុមការងារសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា រួមទាំងក្មេងៗដែលជាកូនៗរបស់បុគ្គលិក និងកូនៗរបស់សាច់ញាត្តិរបស់ពួកគេសរុបទាំងអស់៩៩នាក់។ ក្នុងការឃាត់ខ្លួនយកទៅសាកសួរនោះអាជ្ញាធរបានដកហូតសម្ភារៈ ឧបករណ៍អេឡិចត្រូនិចរបស់ក្រុមការងារទាំងអស់ពេញមួយយប់កាលពីថ្ងៃទី១៧ ខែឧសភា មកដល់ព្រឹកថ្ងៃទី១៨ ខែឆ្នាំដដែល។ បន្ទាប់មកក៏សម្រេចបញ្ជូនមនុស្សចំនួន៣នាក់ត្រឡប់ទៅកាន់ស្នងការដ្ឋានខេត្តរតនគិរីវិញដែលរួមមាន៖ ១.លោក ថេង សារឿន ជាប្រធានសមាគម ២.លោក ប៉ិុល ភាព មន្ត្រីជាន់ខ្ពស់ផ្នែងចងក្រង និងតស៊ូមតិ និង៣.លោក ថាន់ ថាច មន្ត្រីសម្របសម្រួលសហគមន៍របស់សមាគម ។

សហភាពផ្ទះសាមគ្គីយល់ឃើញថា ក្នុងសកម្មភាពសាកសួរដែលមានការដកហូតសម្ភារៈ និងឧបករណ៍អេឡិចត្រូនិចទៅត្រួតពិនិត្យ គឺជាសកម្មភាពរំលោភលើឯកជនភាពយ៉ាងធ្ងន់ធ្ងរ។ ចំពោះការឃាត់ខ្លួនខាងលើនេះ បង្ហាញថាជាទង្វើរំលោភនូវអំណាចរបស់ស្ថាប័នរដ្ឋ និង

រំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរពីសំណាក់អាជ្ញាធររដ្ឋមកលើសមាគម ដែលបាននឹងកំពុងធ្វើការងារយ៉ាងសកម្មលើការលើកកម្ពស់សិទ្ធិមនុស្សជាមូលដ្ឋាន ដើម្បីផលប្រយោជន៍ជនក្រីក្រ និងជនងាយរងគ្រោះ។ នេះជាទង្វើគំរាមកំហែងឥតឈប់ឈររបស់អាជ្ញាធររដ្ឋមកលើអង្គការសង្គមស៊ីវិល និងពលរដ្ឋខ្លួនឯង។ បញ្ហានេះវាមិនមែនជាលើកទី១ទេ ដែលអាជ្ញាធររដ្ឋបានធ្វើទុក្ខបុកម្នេញមកដល់សមាជិកសហភាពផ្ទះសាមគ្គី។

ពាក់ព័ន្ធទៅនឹងបញ្ហានេះ លោកស្រី ចក់ សុភាព នាយិកាប្រតិបត្តិ នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានសរសេរលើបណ្តាញសង្គមផ្ទាល់ខ្លួន នាថ្ងៃទី១៨ ខែឧសភាថា «នេះទើបបិទបញ្ចប់ស៊ីហ្គេមដែលយើងបន្ទរថាប្រទេសតូចបេះដូងធំ ចុះចំពោះសហគមន៍ សមាគម សកម្មជនសិទ្ធិមនុស្ស និងនយោបាយ តើប្រើបេះដូងអ្វីដែរ? តើការជួបជុំដើម្បីពង្រឹងសមត្ថភាព និងឆ្លុះបញ្ចាំងការងាររបស់សមាគម ជាអំពើល្មើសមែនទេ បានត្រូវឃាត់ខ្លួន និងរឹបអូសឧបករណ៍របស់ពួកគេ? »

នាយិកាប្រតិបត្តិ CCRH បន្តអំពាវនាវថា«សូមអាជ្ញាធរអានរដ្ឋធម្មនុញ្ញ និងច្បាប់ពាក់ព័ន្ធដល់ការជួបជុំដែលករណីសិក្ខាសាលាជាដើមមិនមានតម្រូវជូនដំណឹងអាជ្ញាធរមូលដ្ឋានទេ និងជាពិសេសលិខិតតូបករណ៍សិទ្ធិមនុស្សដែលកម្ពុជាទទួលស្គាល់ និងដាក់ចូលក្នុងរដ្ឋធម្មនុញ្ញផងដែរ។ សូមដោះលែងក្រុមការងារសមាគមសម្ព័ន្ធសហគមន៍កសិករ

កម្ពុជាឱ្យពួកគេមានសេរីភាព និងបង្ហាញការប្ដេជ្ញាគោរពដល់លម្ហសង្គមស៊ីវិលផងដែរ!»

ឆ្លើយតបទៅនឹងបញ្ហានេះ លោក ញ៉េម សំអឿន អភិបាលខេត្តរតនគិរី បានប្រាប់វិទ្យុអាស៊ីសេរីនាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ថា ការឃាត់ខ្លួនលោក ថេង សាវឿន ប្រធានសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា និងក្រុមការងាររបស់គេ គ្រាន់តែជាការយកមកបំភ្លឺនោះទេ ចំពោះនីតិវិធីបន្តទៅទៀតលោកមិនទាន់អាចជម្រាបបានទេគិតត្រឹមថ្ងៃទី១៩ ខែឧសភានេះ។ វិទ្យុអាស៊ីសេរីបានព្យាយាមទាក់ទងសុំការបំភ្លឺបន្ថែមពីលោក ស្នងការនគរបាលខេត្តរតនគិរីដែរ ប៉ុន្តែមិនទាន់ទទួលបានការឆ្លើយតប។ សូមបញ្ជាក់ថា អ្នកទាំង៣ខាងលើជាមួយសហការីរបស់ខ្លួនជាង ១០នាក់ រួមនឹងក្រុមគ្រួសារពួកគេ ត្រូវបាននគរបាលខេត្តក្រចេះឃាត់ខ្លួនសាកសួរ បន្ទាប់ពីចូលរួមសិក្ខាសាលា ការកសាងក្រុម និងពង្រឹងសមត្ថភាពបុគ្គលិក កាលពីថ្ងៃ១៧ ខែឧសភា។ បើតាមលោក ញ៉េម សំអឿន បញ្ជាក់ប្រាប់វិទ្យុបារាំងអន្តរជាតិ ការឃាត់ខ្លួនដោយសារតែពួកគេបានធ្វើសកម្មភាពការងារនៅខេត្តរតនគិរី ហាក់ប្រាស់ចាកពីច្បាប់ដែលគួរឱ្យសង្ស័យ៕